ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៦

ដំណឹងជ្រើសរើសអ្នកស្ម័គ្រចិត្ត

អង្គការស្អាតកម្ពុជា ជាអង្គការគ្រិស្តបរិស័ទក្នុងស្រុកមួយ ដែលបាននិងកំពុងអនុវត្តគម្រោងក្រោមគោលបំណងទឹកស្អាត និងអនាម័យ (WASH)។ បេសកកម្មគឺ ដើម្បីលើកកំពស់គុណភាពទឹក អនាម័យ សុខភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងបណ្តាសហគមន៍គោលដៅដោយប្រើបច្ចេកវិទ្យា និងការអប់រំសមស្រប។ ការងារទាំងអស់ត្រូវបានធ្វើឡើងដោយសហការជាមួយថ្នាក់ដឹកនាំសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ អង្គការស្អាតកម្ពុជាបច្ចុប្បន្នកំពុងអនុវត្តគម្រោងរបស់ខ្លួននៅក្នុងខេត្តចំនួន ១១ ដូចជា ស្វាយរៀង ព្រៃវែង កំពង់ធំ បាត់ដំបង ពោធិ៍សាត់ ឧត្តរមានជ័យ សៀមរាប ត្បូងឃ្មុំ កំពង់ស្ពឺ រតនគិរី និងស្ទឹងត្រែង។អង្គការស្អាតកម្ពុជាត្រូវការជ្រើសរើសអ្នកស្ម័គ្រចិត្តរយៈពេលវែងចំនួន ០១នាក់ សម្រាប់មុខតំណែងជា **អ្នកស្ម័គ្រចិត្តផ្នែកបច្ចេកទេសទឹកស្អាត និងអនាម័យសាលារៀន(** School WASH Technical Volunteer) ដែលមានទីតាំងការិយាល័យនៅ**ភូមិថ្ម្ល់ជប៉ុន សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។**

១. ការទទួលខុសត្រូវក្នុងមុខតំណែង ៖

- រៀបចំតំឡើង ធុងចម្រោះឲ្យបានត្រឹមត្រូវ ដោយមានការចូលរួមពីសាលាដែលទទួលផល។
- ជួយគាំទ្រដល់ការបង្រៀនគ្រួសារ និងក្រុមជំនុំឲ្យយល់អំពីអនាម័យនិងទឹកស្អាត។
- ពន្យល់ដល់គ្រួសារទទួលផល អំពីដំណើរការនៃការថែរក្សាអណ្តូងស្នប់ឲ្យបានត្រឹមត្រូវ និងបំផុសស្មារតីម្ចាស់ការ។
- ជួយដល់តំណាងអង្គការស្អាតកម្ពុជា ផ្នែកកិច្ចការរដ្ឋបាល ក្នុងការរៀបចំការកត់ត្រា ដែលតំឡើងហើយ និងបញ្ចូលទៅក្នុងប្រព័ន្ធ GPS និង iForm Builder ។
- ធ្វើការប៉ាន់ប្រមាណ ដោយផ្ទាល់មាត់អំពីការប្រើប្រាស់ធុងចម្រោះ សាលារៀនដល់តំណាងអង្គការស្អាតកម្ពុជា។
- បំពេញការងារផ្សេងៗ ទៀតទៅតាមតម្រូវការ របស់ប្រធានប្រចាំខេត្តស្នើសុំ។
- ជួយបង្រៀន និងណែនាំពីការប្រើប្រាស់ ធុងចម្រោះ ដល់សហគមន៍ និងសាលារៀន។

២. លក្ខខណ្ឌជ្រើសរើស៖

- បញ្ចប់ថ្នាក់វិទ្យាល័យ ឬមានតម្លៃស្មើ។
- មានបទពិសោធន៍ក្នុងការធ្វើការងារសហគមន៍ ឬសំណង់ផ្សេងៗ។
- ប្រកាន់ខ្ជាប់នូវតម្លៃ និងបេសកកម្មរបស់អង្គការស្អាតកម្ពុជា។
- មានក្រមសិលធម៌ការងារជាអាជីព។ មានបំណងចង់ធ្វើការងារសហគមន៍។
- មានម៉ូតូផ្ទាល់ខ្លួន និងមានឆន្ទៈក្នុងការជិះម៉ូតូតាមសហគមន៍។

ចំពោះបេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ជាមួយមុខតំណែងនេះ សូមមកទទួលយកពាក្យសុំធ្វើការងារនៅ ការិយាល័យ ខេត្ត **ខេត្តពោធិ៍សាត់** ឬអាចទាញយកពាក្យសុំបម្រើការងារជាភាសា ខ្មែរ ឬ អង់គ្លេស ទៅបំពេញហើយបញ្ជូនមកវិញដោយភ្ជាប់ជាមួយ ប្រវត្តិរូបសង្ខេប (CV & Cover Letter) រួចបញ្ជូនមកកាន់ការិយាល័យ **ខេត្តពោធិ៍សាត់** តាមរយៈអាសយដ្ឋាន**ខាងលើ** ឬទំនាក់ទំនងទូរស័ព្ទលេខ: (**៨៨៥**)-**២៣ ៨៨០ ១៦៤**, Email: hr@clearcambodia.org,Website: www.clearcambodia.org.

<u>សំគាល់:</u> សូមភ្ជាប់មកជាមួយនូវឯកសារថតចំលង អត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត ប័ណ្ណគ្រួសារ ឬសៀវភៅស្នាក់នៅ និង ឯកសារពាក់ព័ន្ធផ្សេងទៀត និង រូបថត ៤X៦ ចំនួន ២សន្លឹក។

បន្ទាប់ពីពិនិត្យលើសំណុំបែបបទសុំបំរើការងារអ្នកជាប់បញ្ជីសម្រាំងនិងត្រូវបានធ្វើការទំនាក់ទំនង ដើម្បីធ្វើការសម្ភាសន៍។

ថ្ងៃផុតកំណត់ទទួលពាក្យនៅ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៦ ។